DOING BUSINESS IN #LOWELL THERE'S A LOT TO like.




## មូលនិធិជួយសង្គ្រោះអាជីវកម្មខ្នាតតូចនៅទីក្រុងឡូវែល ដោយសារកូវីត - លើកទី ២

សាលាក្រុងឡូវែល បានបង្កើតមូលនិធិជំនួយអាជីវកម្មខ្នាតតូច កូវីត-១៩ ចំនួន ៥០០,០០០ ដុល្លារ ដើម្បីជួយដល់សហគ្រាសអាជីវកម្មនៅទីក្រុងឡូវែល ដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ និង បានរងផលប៉ះពាល់អវិជ្ជមានដោយសារជំងឺរាតត្បាត កូវីត-១៩ ។

**ទិដ្ឋភាពទូទៅ**

ជំនួយទូទៅ (ប្រមាណជា ៥០០,០០០ ដុល្លារ) ជាប្រាក់កម្ចីដែលអាចលើកលែងបាន (forgivable loan)
ប្រាក់កម្ចីដែលអាចលើកលែងបានចំនួន ៥,០០០ ដុល្លារ អាចប្រើបានដើម្បីទូទាត់ការចំណាយលើដំណើរការនៃអាជីវកម្មរួមមាន ថ្លៃជួល រឺ បង់រំលស់អគារ ការចំណាយលើប្រាក់ខែបុគ្គលិក បូករួមទាំងសេវាថែទាំសុខភាព ការចំណាយលើការប្រើប្រាស់ ទឹក, អគ្គិសនី, ហ្គាស, ឬ ថ្លៃសេវាផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្ម ។

**លក្ខណៈវិនិច្ឆ័យដើម្បីអាចស្នើសុំ**

- អាជីវកម្មខ្នាតតូចគ្រប់គ្រងដោយឯករាជ្យ
- អាជីវកម្មដែលមានមូលដ្ឋាននៅទីក្រុងឡូវែល
- អាជីវកម្មដែលលក់ រឺ ផ្តល់សេវាកម្ម នៅក្នុងអគារថ្ម
- អាជីវកម្មបានដំណើរការនៅឡូវែលមុនថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០២០
- អាជីវកម្មត្រូវតែដំណើរការចេញពីទីតាំងសំណង់អគារថ្ម ហើយមាននិយោជិកពេញម៉ោងយ៉ាងតិចមួយ (១) នាក់ រឺ ស្មើនឹងពេញម៉ោងក្នុងកំឡុងឆ្នាំ ២០១៩ ដោយមិនរាប់បញ្ចូលម្ចាស់អាជីវកម្ម ។
  - បុគ្គលិកពេញម៉ោងត្រូវបានគេចាត់ទុកថាជាអ្នកដែលធ្វើការយ៉ាងតិច 30 ម៉ោងក្នុងមួយសប្តាហ៍។
- បង្ហាញថាបានខាតបង់ ២៥% នៃប្រាក់ចំណូលសម្រាប់ខែមីនាឆ្នាំ ២០២០ (ប្រៀបធៀបទៅនឹងខែមីនា ឆ្នាំ ២០១៩)
  - សម្រាប់អាជីវកម្មដែលបានបើកដំណើរការក្រោយ ខែមីនាឆ្នាំ ២០១៩ អ្នកនឹងតម្រូវឲ្យ ចងក្រងឯកសារអំពីការខាតបង់ប្រាក់ចំណូលក្នុងរយៈពេល ៨ ខែចុងក្រោយ ។
- រក្សានិយោជិកពេញម៉ោង យ៉ាងហោចណាស់មួយ (១) នាក់ រឺ ស្មើនឹងពេញម៉ោង ដែលនៅទទួលប្រាក់ខែ (មិនរាប់បញ្ចូលម្ចាស់អាជីវកម្ម)
- អាជីវកម្មនៅសល់យ៉ាងហោចណាស់មួយ (១) ឆ្នាំ នៅលើកិច្ចសន្យាជួល ឬភស្តុតាងនៃកម្មសិទ្ធិអចលនទ្រព្យពាណិជ្ជកម្ម

**តម្រូវការនៃកម្មវិធីជំនួយ HUD Community Development Block Grant ហៅកាត់ថា (CDBG)**

អ្នកស្នើសុំជំនួយប្រភេទណាមួយក៏ដោយ ត្រូវតែបំពេញតាមតម្រូវការនៃកម្មវិធីជំនួយអភិវឌ្ឍន៍សហគមន៍ របស់នាយកដ្ឋានលំនៅដ្ឋាន និង នគរូបនីយកម្មនៃសហរដ្ឋអាមេរិក (U.S Department of Housing & Urban Development Community Development Block Grant program) ។

អ្នកដាក់ពាក្យស្នើសុំត្រូវតែបំពេញតាមគោលបំណងថ្នាក់ជាតិរបស់ HUD ថាជាសហគ្រាសខ្នាតតូចដែលមានល័ក្ខខ័ណ្ឌសមស្រប ឬ ជាគំរោងបង្កើត / រក្សាការងាររអោយបុគ្គលិកដែលមានប្រាក់ចំណូលតិច / មធ្យម៖

**សហគ្រាសខ្នាតតូច**

អាជីវកម្ម ត្រូវមាននិយោជិកពេញម៉ោងចំនួនប្រាំនាក់ (៥) រឺ តិចជាងនេះ ហើយ
ម្ចាស់អាជីវកម្មត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃប្រាក់ចំណូលជាមធ្យមនៅក្នុងគ្រួសារ។ ប្រាក់ចំណូលក្នុងគ្រួសារសរុប របស់ម្ចាស់អាជីវកម្មត្រូវតែស្ថិតនៅ ឬ ក្រោម ៨០% នៃប្រាក់ចំណូលជាមធ្យមរបស់គ្រួសារទូទៅនៅក្នុងតំបន់ ដើម្បីមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលបានជំនួយនេះ ។

**ការបង្កើតការងារ ឬ ការរក្សាការងារ**

អ្នកដាក់ពាក្យស្នើសុំ ត្រូវវតែប្តេជ្ញាបង្កើត ឬ រក្សាទុកយ៉ាងហោចណាស់ការងារពេញម៉ោងមួយ (ឬស្មើនឹងពេញម៉ោង) (១) ។ ការងារត្រូវតែបំពេញដោយបុគ្គលដែលមានលក្ខណៈសមស្របតាមល័ក្ខខ័ណ្ឌតម្រូវនៃប្រាក់ចំណូលជាមធ្យមនៅក្នុងគ្រួសារ។ ប្រាក់ចំណូលសរុបក្នុងគ្រួសាររបស់បុគ្គលនោះ ត្រូវតែមាន ឬ តិចជាង ៨០% នៃប្រាក់ចំណូលជាមធ្យមរបស់គ្រួសារទូទៅនៅក្នុងតំបន់ ដើម្បីបំពេញនូវល័ក្ខខ័ណ្ឌបានគ្រប់គ្រាន់ ។

ជួលឡើងវិញនូវ និយោជិកដែលត្រូវបានបញ្ឈប់នាពេលថ្មីៗ ដោយសារផលប៉ះពាល់ដែលទាក់ទងនឹងកូវីត-១៩ យ៉ាងហោចណាស់មួយមុខតំណែង ឬ រក្សានិយោជិកដែលត្រូវបានបញ្ឈប់បណ្តោះអាសន្ន ណាម្នាក់ដែលមានប្រាក់ចំណូលសមស្របនឹងល័ក្ខខ័ណ្ឌតម្រូវនេះ ។

**សម្គាល់**: ប្រសិនបើអាជីវកម្មរបស់អ្នក មាននិយោជិកពេញម៉ោងចំនួន ៥ នាក់ ឬតិចជាងនេះ ប៉ុន្តែអ្នកមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃប្រាក់ចំណូលគ្រួសារ ឬ អ្នកមិនមានលទ្ធភាពជួល ឬ រក្សាទុកនិយោជិកដែលប្រាក់ចំណូលរបស់គាត់សមស្របនឹងល័ក្ខខ័ណ្ឌរបស់ HUD ក្នុងរយៈពេល ៦ ខែបន្ទាប់ពីទទួលបានប្រាក់កម្ចី នោះអ្នកនឹងមិនមានសិទ្ធិទទួលបានការលើកលែងចំពោះប្រាក់កម្ចីនេះទេ ។

**ជំនួយទូទៅសម្រាប់អាជីវកម្មនៅទីក្រុងឡូវែលដែលរងផលប៉ះពាល់**

សាលាក្រុងឡូវែល នឹងផ្តល់ជំនួយរហូតដល់ ៥,០០០ ដុល្លារ ដោយជ្រើសរើសអាជីវកម្មណាដែលមានលក្ខណៈសមស្របនឹងទទួលបាន។ កញ្ចប់ជំនួយនឹងត្រូវប្រើប្រាស់ដើម្បីទូទាត់សង ការចំណាយដែលត្រឹមត្រូវ និងជាទម្រង់នៃប្រាក់កម្ចីដែលអាចលើកលែងបាន។ ប្រាក់កម្ចីនឹងត្រូវបានលើកលែង នៅពេលដែលសាលាក្រុងអាចបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាំងអស់របស់កម្មវិធីជំនួយ HUD CDBG-CV ។

**អាជីវកម្មដែលមិនមានសិទ្ធិទទួលបាន**

- មិនបានបំពេញតាមគោលការណ៍ណែនាំប្រាក់ចំណូលដែលបានរៀបរាប់ខាងលើ
- មិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃការបង្កើតការងារ / ការរក្សាការងារ ឬ ល័ក្ខខ័ណ្ឌតម្រូវនៃសហគ្រាសខ្នាតតូច
- អង្គការមិនស្វែងរកប្រាក់ចំណេញ ឬ ស្ថាប័នដែលផ្អែកលើជំនឿសាសនា ឬ ជំនឿផ្សេងៗ

- ម្ចាស់សហគ្រាសឯកកម្មសិទ្ធិដែលគ្មានទីតាំងអាជីវកម្មនៅក្នុងអគារថ្មី
- ប្រភេទអាជីវកម្មខាងក្រោម មិនមានសិទ្ធិទទួលបានមូលនិធិជំនួយរបស់សហព័ន្ធនោះទេ ដែលនេះត្រូវបានហាមឃាត់ដោយ HUD៖ អាជីវកម្មកញ្ឆា, ហាងលក់ស្រា, ហាងបញ្ចាំ, ហាងលក់ផលិតផល វី ផ្តល់សេវាកម្មទាក់ទងនឹងផ្លូវភេទ (adult entertainment), ហាងលក់ថ្នាំជក់, ហាងលក់រថយន្តដែលប្រើរួច, អចលនទ្រព្យ, ធានារ៉ាប់រង, ការិយាល័យច្បាប់, ឬ អាជីវកម្មតាមរដូវកាល ដូចជា ការរៀបចំពន្ធជាដើម ។
- អាជីវកម្មដែលមានបំណុលពន្ធហួសកាលកំណត់, សិទ្ធិកាន់កាប់ពន្ធដែលមានតាំងពីមុនពេលកូវីត-១៩, ឬ អ្នកដែលបានដាក់ពាក្យក្ស័យធន (bankruptcy)
- មិនមានការចុះបញ្ជីអាជីវកម្មត្រឹមត្រូវ / បច្ចុប្បន្ន ជាមួយក្រុង / រដ្ឋ

**ការប្រើប្រាស់មូលនិធិជំនួយដែលត្រឹមត្រូវ**

- កញ្ចប់ជំនួយអាចប្រើសម្រាប់ចំណាយលើដំណើរការអាជីវកម្មដែលមានដូចជា៖ ការចំណាយលើថ្លៃជួល ឬ បង់រំលស់អគារ ការប្រើប្រាស់ ទឹក, អគ្គិសនី, ហ្គាស, និង ថ្លៃសេវាផ្សេងៗដែលទាក់ទងនឹងអាជីវកម្ម ។

**កាលបរិច្ឆេទផុតកំណត់នៃការដាក់ពាក្យ: ថ្ងៃទី ២២ ខែមករា ឆ្នាំ ២០២១ @ ១២:០០ ថ្ងៃត្រង់។**

- ពាក្យស្នើសុំដែលទទួលបានតាមថ្ងៃកំណត់ នឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីមានសិទ្ធិទទួលបានប្រាក់ជំនួយពីកម្មវិធីនេះ។

**ការពិចារណាបន្ថែម**

- អាជីវកម្មខ្នាតតូចដែលជាកម្មសិទ្ធិរបស់ជនជាតិដើមភាគតិច នឹងត្រូវបានផ្តល់អាទិភាព ក៏ដូចជាអាជីវកម្មខ្នាតតូចដែលមិនបានដាក់ពាក្យស្នើសុំ ឬ បានទទួលមូលនិធិជំនួយណាមួយពីកម្មវិធីក្នុង ស្រុក, រដ្ឋ, និងសហព័ន្ធ ។
- សូមកត់សម្គាល់ថា រាល់អាជីវកម្មទាំងអស់ដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យដូចរៀបរាប់ខាងលើ ក៏មិនធានាថានឹងទទួលបានកញ្ចប់ជំនួយនេះទេ ដោយសារតែថវិការនៃកម្មវិធីនេះមានកំរិត ។ សាលាក្រុង សូមរក្សាសិទ្ធិក្នុងការបញ្ឈប់ ឬ កែប្រែលក្ខខ័ណ្ឌតម្រូវ និង ថវិកាក្នុងករណីដែលចាំបាច់ ។

**ការជូនដំណឹង**

- បេក្ខជនដែលទទួលបានជោគជ័យ នឹងទទួលបានសេចក្តីជូនដំណឹងអំពីរង្វាន់ពីសាលាក្រុងឡូវែល តាមរយៈអ៊ីមែលរួមជាមួយការណែនាំអំពីជំហានបន្ទាប់ ។
- បេក្ខជនដែលមិនទទួលបានជោគជ័យ នឹងត្រូវជូនដំណឹងតាមអ៊ីមែល ។

**ការផ្តល់មូលនិធិជំនួយ**

- ខណៈពេលដែលចំនួនទឹកប្រាក់ផ្តល់កម្ចីមានចំនួន ៥,០០០ ដុល្លារ  ចំនួនទឹកប្រាក់ជំនួយជាក់ស្តែង គឺអាស្រ័យលើភស្តុតាងដែលអាចផ្ទៀងផ្ទាត់បាន។ ឧទាហរណ៍ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំ អាចចងក្រងឯកសារបង់ថ្លៃជួលពាណិជ្ជកម្មតែមួយខែម្តង នោះទឹកប្រាក់រង្វាន់ នឹងស្មើនឹងទំហំនៃការចំណាយលើថ្លៃជួលពាណិជ្ជកម្មនោះ ។
- សាលាក្រុងឡូវែល នឹងទាមទារព័ត៌មានហិរញ្ញវត្ថុបន្ថែម ដើម្បីចៀសវាងការផ្តល់សេវាកម្មស្ទួន។ ព័ត៌មានបន្ថែម មានដូចជា SAMS #, DUNS# និង ឯកសារហិរញ្ញវត្ថុដែលទទួលបានពីមូលដ្ឋានស្រុក, រដ្ឋ, និង ស្ថាប័នសហព័ន្ធផ្សេងៗ ។